# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Nov-2021, 14:26
CMS/CFO: Sann Rada

## <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំឲ្យបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

សូ មូស្សេន្ទី
Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

ជា លាង
Brenda J HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៤**

លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមដាក់ *ការឆ្លើយតបរបស់ខ្លួន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំឲ្យបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ* ("ការឆ្លើយតប" និង "ចម្លើយតបរបស់ ស.ព.អ")។ ចម្លើយតបរបស់ ស.ព.អ គួរត្រូវបានបដិសេធចោល ដោយសារ ស.ព.អ ស្នើសុំឲ្យដោះស្រាយជាថ្មីដែលមិនអាចអនុញ្ញាតឲ្យបាន ចំពោះបញ្ហានានាដែលអង្គបុរេជំនុំជម្រះ ("អ.ប.ជ") និងអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសម្រេចរួចហើយ ដោយមិនបានផ្តល់សំអាងហេតុដែលអាចទទួលយកបាន ដើម្បីឲ្យងាកចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាំងនោះ ដោយបង្ហាញម្តងហើយម្តងទៀតនូវការប្រឆាំងជាមូលដ្ឋានទៅនឹងវិធាន ការមិនគោរព និងការមិនអនុវត្តតាមសេចក្តីសម្រេចតាមផ្លូវតុលាការនៅ អ.វ.ត.ក និងការមិនអើពើចំពោះសិទ្ធិរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ មេធាវីការពារក្តីស្នើសុំដាក់ការឆ្លើយតបនេះជាភាសាអង់គ្លេសជាមុន ហើយសំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ អ.ប.ជ បានចេញ *សេចក្តីពិចារណារបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ក្នុងសំណុំរឿង ០០៤ ("សេចក្តីពិចារណារបស់ អ.ប.ជ")[2]។

2. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ស.ព.អ បានបញ្ជូនសំណើមួយទៅ អ.ជ.ត.ក តាមរយៈសារអេឡិចត្រូនិក ដោយស្នើសុំពន្យារពេលដាក់សារណាជូន អ.ជ.ត.ក ពាក់ព័ន្ធនឹងអ្វីដែល ស.ព.អ បានអះអាងថា "ជាធម្មតា សារណានេះរំពឹងថានឹងដាក់ [...] ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃបានទទួលសេចក្តីពិចារណាលើសំណុំរឿង ០០៤"[3]។

3. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ មេធាវីការពារក្តីបានឆ្លើយតបតាមសារអេឡិចត្រូនិក ដោយបដិសេធការអះអាងរបស់ ស.ព.អ ថា សេចក្តីពិចារណារបស់ អ.ប.ជ គឺជាសេចក្តីសម្រេច

[1] *សូមមើល* សារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសា ផ្ញើជូនមេធាវីការពារក្តី "ការបកប្រែសំណើ" ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១។

[2] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 និង D382/43។

[3] សារអេឡិចត្រូនិកពីសហព្រះរាជអាជ្ញាអន្តរជាតិ "សំណើរបស់ ស.ព.អ សុំពេលវេលាបន្ថែមដើម្បីដាក់សារណាក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។

ដែលអាចប្តឹងសាទុក្ខទៅ អ.ជ.ត.ក បាន ហើយថា ជាការចាំបាច់ដែលត្រូវស្តាប់មតិយោបល់របស់មេធាវីការពារក្តីជាមុនសិន មុននឹងសម្រេចលើបញ្ហានេះ[4]។

4. នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ អ.ជ.ត.ក បានចេញ *សេចក្តីសម្រេចរបស់ខ្លួនលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលដាក់សារណាពាក់ព័ន្ធនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤*[5]។

5. នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ មេធាវីការពារក្តីបានដាក់*សំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ* ("សំណើរបស់មេធាវីការពារក្តីចំពោះ ស.ច.ស") ជាភាសាអង់គ្លេស ដែលបានជូនដំណឹងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១[6]។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១។

6. ទោះជាយ៉ាងណាក្តី ដោយពុំបានគិតដល់អត្ថិភាពនៃស្ថាប័នតុលាការដែលកំពុងបំពេញការងារយ៉ាងពេញលេញនៅ អ.វ.ត.ក ដូចជា ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") អ.ប.ជ និង អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ស.ព.អ បានដាក់បណ្តឹងសាទុក្ខរបស់ខ្លួនទៅ អ.ជ.ត.ក ដែលបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១[7]។

---

4 សារអេឡិកត្រូនិកពីក្រុមមេធាវីការពារក្តី "កម្មវត្ថុ: សំណើរបស់ក្រុមមេធាវីការពារក្តីសុំពេលវេលាបន្ថែមដើម្បីដាក់សារណាក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។

5 *សាលដីកាសម្រេចលើណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពេលវេលាបន្ថែមដើម្បីដាក់សារណារបស់ខ្លួនទាក់ទងនឹងសេចក្តីពិចារណាររបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ 2/2។

6 *សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ឯកសារ D386។

7 *បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក* ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ឯកសារលេខ 2។

7. នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ មេធាវីការពារក្ដីបានដាក់*ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្តិ អ.វ.ត.ក*[8]។

8. នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួន ដែលបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១[9]។

## II. ស.ព.អ អះអាងដោយខុសឆ្គងថា សំណើមិនអាចទទួលយកបាន

9. ស.ព.អ អះអាងដោយខុសឆ្គងថា លទ្ធភាពគតិយុត្តិទាំងអស់មិនទាន់ប្រើប្រាស់អស់ទេ ដោយសារ "យឹម ទិត្យ បានដឹងថា ស.ព.អ មានបំណងប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល [...]"[10]។ អ.ជ.ត.ក ពុំមែនជា "មធ្យោបាយគតិយុត្តិសម្រាប់ការអនុវត្តស្របតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក" ទេ ដោយសារ អង្គជំនុំជម្រះនេះពុំមានយុត្តាធិការសម្រេចទៅលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់ អ.ប.ជ ទេ ដូចបានឆ្លុះបញ្ចាំងនៅក្នុងវិធាន ៧៧(១៣) និងសេចក្ដីពិចារណាជាឯកច្ឆន្ទរបស់ អ.ប.ជ[11]។ ទោះបី អ.ជ.ត.ក មានយុត្តាធិការក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី ក្នុងកាលៈទេសៈតិចតួចមួយចំនួនក៏ដោយ តែអាជ្ញាបញ្ញាដែលបានបង្ខំឲ្យ អ.ជ.ត.ក ប្រើប្រាស់យុត្តាធិការនេះដើម្បីសម្រេចឲ្យបានសច្ចភាពផ្លូវច្បាប់ និងជាចុងក្រោយនៅក្នុងសំណុំរឿង ០០៤/២ ពុំមានអត្ថិភាពក្នុងសំណុំរឿង ០០៤ ទេ ដោយសារ នាពេលនេះ ក.ស.ច.ស កំពុងបំពេញការងារយ៉ាងពេញលេញ[12]។ នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន ស.ព.អ មិនបានជូនដំណឹងដល់ អ.ជ.ត.ក ថា ស.ច.ស ត្រូវបានប្ដឹងអំពីសំណុំរឿង ០០៤ បន្ទាប់ពីមានការចេញសេចក្ដីពិចារណារបស់

---

[8] *ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក* ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកសារលេខ 2/1 ("ចម្លើយតបរបស់ យឹម ទិត្យ")។

[9] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំឲ្យបញ្ចប់ បោះត្រា និង បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ* ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកសារ D386/1។

[10] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣-៤។

[11] សេចក្ដីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ៤៩។

[12] *សូមមើល* សំណុំរឿង ០០៤/២ *សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 ("សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០៤/២") កថាខណ្ឌ ៥៧ និង ៦៥។

អ.ប.ជ[13]។ ដូចស្ថាប័នតុលាការទាំងអស់នៅ អ.វ.ត.ក ដែរ អ.ជ.ត.ក អាចប្រើប្រាស់យុត្តាធិការរបស់ខ្លួនបាននៅពេលដែលស្របទៅនឹងយុត្តាធិការចម្បងរបស់ខ្លួន តែប៉ុណ្ណោះ[14]។ ស.ច.ស មានយុត្តាធិការ *ចម្បង*និង*ផ្តាច់មុខ* អនុលោមតាមវិធាន ៧៧(១៣) និង សេចក្តីសន្និដ្ឋានជាឯកច្ឆ័ន្ទរបស់ អ.ប.ជ[15]។ ជាងនេះទៀត ស.ព.អ មិនបានបង្ហាញសំអាងហេតុដែលអាចទទួលយកបានដើម្បីឲ្យ អ.ជ.ត.ក ងាកចេញពីការយល់ឃើញរបស់ខ្លួនដែលបានបង្កើតឡើងក្នុងសំណុំរឿង ០០៤/២ ឬ កំហុសអង្គច្បាប់ ឬកាលៈទេសៈផ្លាស់ប្តូរ ដែលជំរុញឲ្យ អ.ជ.ត.ក ត្រូវធ្វើការពិនិត្យឡើងវិញទៅលើបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់គាត់នោះទេ[16]។ ទោះបីមេធាវីការពារក្តីដឹងថា ស.ព.អ មានបំណងចង់ឲ្យ អ.ជ.ត.ក ទទួលយកសំណុំរឿងទៅពិនិត្យ ឬយ៉ាងណានោះ គឺពុំពាក់ព័ន្ធឡើយ។

10. ស.ព.អ អះអាងដោយខុសឆ្គងថា ស.ច.ស មិនត្រូវបានប្តឹងអំពីសំណុំរឿង ០០៤ ទេ[17]។ អ.ប.ជ បានបញ្ជូនសំណុំរឿងត្រឡប់ទៅ ស.ច.ស វិញបន្ទាប់ពីបានចេញសេចក្តីពិចារណារបស់ខ្លួន ដោយបានសម្រេចមិនធ្វើការស៊ើបអង្កេតសំណុំរឿងនេះដោយខ្លួនឯង ឬចេញដីកាដំណោះស្រាយដោយខ្លួនឯង អនុលោមទៅតាមសិទ្ធិអំណាចរបស់ខ្លួនដូច "សភាស៊ើបសួរកម្ពុជានៅ អ.វ.ត.ក" ឬអនុលោមតាមសេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីបានប្រកាសថាការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់[18]។ ដោយលុបបំបាត់វិមតិសង្ស័យថាតើស្ថាប័នមួយ

---

[13] ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ២៤។ សេចក្តីពិចារណារបស់ អ.ប.ជ ទំព័រ ៦៥ កថាខណ្ឌ ១១១។ សំណុំរឿង ០០៣ *សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣* ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D271/5 និង D272/3 "សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣") កថាខណ្ឌ ៧២។

[14] *សូមមើល* សំណុំរឿង ០០២ *សេចក្តីសម្រេចលើសំណើរស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ* ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ E286/2/1/2 កថាខណ្ឌ ១២។ *សូមមើល* សំណុំរឿង ០០២ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើង* នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ E463/1/3 កថាខណ្ឌ ១៧។

[15] សំណើរបស់ក្រុមមេធាវីការពារក្តីទៅកាន់ ក.ស.ច.ស កថាខណ្ឌ ៧-១២។ ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ២០-២៦។

[16] ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ២៧-៣១។

[17] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥។

[18] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦១ យោងទៅសេចក្តីពិចារណាលើសំណុំរឿង ០០៤/២ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 កថាខណ្ឌ ៣០ (កត់សម្គាល់ថា អ.ប.ជ បានសម្រេចថា ខ្លួនមានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយថ្មី ឬ

ណានៅ អ.វ.ត.ក ទទួលយកមកពិនិត្យ បន្ទាប់ពីមានការចេញសេចក្តីពិចារណារបស់ខ្លួននោះ អ.ប.ជ បានបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង ០០៣ ថា ស.ច.ស "ទទួលខុសត្រូវដំណើរការសំណុំរឿង" និង អនុវត្តតាមសេចក្តីពិចារណារបស់ អ.ប.ជ "ភ្លាម"[19]។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៣ ស.ច.ស បានបញ្ជាក់ច្បាស់ថា ពួកគាត់ពិចារណាបើកដំណើរការការិយាល័យរបស់ខ្លួនយ៉ាងពេញលេញ ហើយថាការិយាល័យមានអំណាចបញ្ចប់ បោះត្រា និង បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ[20]។

11. ស.ព.អ អះអាងដោយខុសឆ្គងថា ស.ច.ស ពុំមានយុត្តាធិការទេ[21]។ សំណើពុំបានអះអាងថា ស.ច.ស មានយុត្តាធិការនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីទេ។ ផ្ទុយទៅវិញ មេធាវីការពារក្តីលើកឡើងថា ស.ច.ស មានយុត្តាធិការ*ចម្បង*និង*ផ្តាច់មុខ*ផ្អែកលើវិធាន ៧៧(១៣) និង សេចក្តីសន្និដ្ឋានជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថា ដីកាដំណោះស្រាយពីរត្រូវបានចេញដោយខុសច្បាប់ មានន័យថាដីកាដំណោះស្រាយទាំងពីរត្រូវទុកជាមោឃៈ[22] ដែលបន្ទាប់មក អ.ប.ជ បានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនជា "សភាស៊ើបសួរនៅ អ.វ.ត.ក" ដើម្បីបញ្ជូនសំណុំរឿងត្រឡប់ទៅ ស.ច.ស ឲ្យដំណើរការ អនុលោមតាមសេចក្តីពិចារណារបស់ អ.ប.ជ[23]។

12. ស.ព.អ អះអាងដោយមានកំហុសថា ស.ច.ស ពុំមានសិទ្ធិអំណាចផ្លូវច្បាប់ច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ[24]។ នៅក្នុងសំណុំរឿង ០០៤ ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនោះទេ។ ដីកាដំណោះស្រាយទាំងពីរត្រូវបានចេញដោយខុសច្បាប់[25]។ ស.ច.ស បានគាំទ្រទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលបានលើកឡើងចាប់តាំងពីពេលប្តឹងឧទ្ធរណ៍ប្រឆាំង

---

កែប្រែដីកាដំណោះស្រាយនោះ និងថា ខ្លួនបំពេញតួនាទីស៊ើបអង្កេតខាងភាគីកម្ពុជានៅ អ.វ.ត.ក មានន័យថាខ្លួន "ត្រូវស៊ើបអង្កេតដោយខ្លួនឯង" នៅពេលទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ)។ សេចក្តីពិចារណាលើសំណុំរឿង ០០៤ ទំព័រ ៦៩។

[19] សេចក្តីសម្រេចរួមក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៧២។

[20] សំណុំរឿង ០០៣ *ដីកាបង្គាប់ឲ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣* ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ D273។

[21] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៦។

[22] សំណើរបស់ក្រុមមេធាវីការពារក្តីទៅកាន់ ក.ស.ច.ស កថាខណ្ឌ ១៤-១៦។

[23] សំណើរបស់ក្រុមមេធាវីការពារក្តីទៅកាន់ ក.ស.ច.ស កថាខណ្ឌ ៨-១២។

[24] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៧។

[25] សំណើរបស់ក្រុមមេធាវីការពារក្តីទៅកាន់ ក.ស.ច.ស កថាខណ្ឌ ៣៩។ ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ២៧-៤០។

នឹងដីកាដំណោះស្រាយចំនួនពីរ[26] ដោយបានពន្យល់នៅក្នុងសំណុំរឿង ០០៣ ថា "កំហុសនីតិវិធីនៃដីកា ដែលមានស្ថានទម្ងន់បែបនេះនៅក្នុងសេចក្តីសម្រេចណាមួយក្នុងដំណាក់កាលស៊ើបអង្កេតប្រាកដណាស់នឹងនាំទៅដល់ការធ្វើមោឃភាពដីកានោះ ហើយចាំបាច់ត្រូវលុបចេញពីសំណុំរឿងដោយសារតែមោឃភាព" ហើយ "គោលជំហរដ៏គួរឱ្យភ្ញាក់ផ្អើល ដែលប្រកាន់យកដោយចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ដែលថាកំហុសនេះ មិនធ្វើឱ្យដីកាដំណោះស្រាយមោឃៈដោយខ្លួនឯងនោះ គឺពិតជាពិបាកយល់ណាស់ [...]"[27]។ មេធាវីការពារក្តីមិនបានស្នើសុំ ស.ច.ស "ឱ្យមោឃៈដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព" ដូចដែល ស.ព.អ បានអះអាងដោយមានកំហុសនោះទេ[28] ប៉ុន្តែស្នើសុំឱ្យទទួលស្គាល់ស្ថានភាពនីតិវិធីដែលកើតមានរួចហើយ និងឱ្យដំណើរការសំណុំរឿងទៅតាមនីតិវិធី។

13. ស.ព.អ សន្និដ្ឋានដោយមានកំហុសថា "ការកំណត់ជាមុនរបស់ ស.ច.ស អំពីថាតើសំណុំរឿងនេះគួរបន្តទៅជំនុំជម្រះដែរឬអត់" ធ្វើឱ្យពួកគេគ្មានគុណវុឌ្ឍិ[29]។ ស.ព.អ ពុំមានសិទ្ធិអំណាចតាមផ្លូវតុលាការដែលបានប្រគល់ជូន អ.ប.ជ អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង ដើម្បីប្រកាសអំពីការប្តឹងជំទាស់ ស.ច.ស នោះទេ។ ស.ព.អ គ្រាន់តែប្រកាសថា ស.ច.ស បានបំពេញកិច្ចដោយមានភាពលំអៀងជាក់ស្តែង *និងលេចឡើងនូវភាពលំអៀង* នៅពេល ស.ច.ស បានស្នើសុំធ្វើសេចក្តីសន្និដ្ឋាននៅក្នុងសំណុំរឿង ០០៣ អំពីករណីថា តើ ស.ច.ស មានយុត្តាធិការនៅសេសសល់ក្នុងការបញ្ចប់សំណុំរឿងដែរឬទេ ដោយពុំចាំបាច់ដាក់សំណើសុំ អនុលោមតាមវិធាន ៣៤(៥) ជាមួយភ័ស្តុតាងគាំទ្រ[30]។ ករណីនេះជាការចោទប្រកាន់លើវិជ្ជាជីវៈយ៉ាងធ្ងន់ធ្ងរ ជាពិសេស ដោយ

---

[26] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 & D382/21 កថាខណ្ឌ ៣៧-៤០។ *សូមមើលផងដែរ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/26 កថាខណ្ឌ ៨-២៦។

[27] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារ D270/7 ("សេចក្តីសម្រេចរបស់ ស.ច.ស លើការបញ្ជូនសំណុំរឿង ០០៣") កថាខណ្ឌ ២១។

[28] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៧។

[29] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៨-៩។

[30] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៩។ សំណុំរឿង ០០៣ *ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣* ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ D273។

សារបានចោទប្រកាន់ ស.ច.ស.អ និង ស.ច.ស.ជ ថាមិនត្រឹមតែបង្ហាញឲ្យឃើញនូវភាពលម្អៀងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង*ពិតជាមានភាព*លម្អៀងជាក់ស្តែង។ ការប្តឹងជំទាស់ចៅក្រមមិនមែនជាកិច្ចដែលត្រូវធ្វើឡើងដោយថើៗនោះទេ ដោយសារត្រូវបំពេញលក្ខខណ្ឌខ្ពស់ ដើម្បីបដិសេធការសន្មតនៃអនាគតិ ដែល "កើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងរបស់គាត់"[31]។ ការអះអាងដោយគ្មានហេតុផលរបស់ ស.ព.អ ខកខានមិនបានបំពេញលក្ខខណ្ឌមួយនេះ។ ដោយសារសហព្រះរាជអាជ្ញាទាំងពីរបានផ្តល់ទឡ្ហីករណ៍តវ៉ានៅពេលជនជាប់ចោទក្នុងសំណុំរឿង ០០២ ស្នើសុំប្តឹងជំទាស់ចៅក្រម អ.ជ.ស.ដ ទាំងអស់ "លក្ខខណ្ឌចាំបាច់ក្នុងការបង្កើតកង្វះខាតនូវភាពអនាគតិនោះគឺការផ្តល់ភស្តុតាងថា ចៅក្រមបានបង្ហាញសេចក្តីលំអៀងមួយដែលមិនត្រូវកន្លែង ឬ ដែលមិនត្រឹមត្រូវប្រឆាំងនឹងជនជាប់ចោទ *ដែលមិនជាប់ទាក់ទងដោយពិតប្រាកដទៅនឹងការអនុវត្តច្បាប់*"[32]។ ជាពិសេស ស.ព.អ មិនបានចោទប្រកាន់អំពីភាពលម្អៀងរបស់ ស.ច.ស ឡើយ នៅពេល ស.ច.ស បានស្នើសុំធ្វើសេចក្តីសន្និដ្ឋានអំពីផលប៉ះពាល់នៃស្ថានភាពថវិការបស់ អ.វ.ត.ក ហើយបានលើកឡើងថា ស.ច.ស កំពុងពិចារណាផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុង[33] ឬ នៅពេល ស.ច.ស.អ បានស្នើសុំធ្វើសេចក្តីសន្និដ្ឋានអំពីអង្គច្បាប់ផ្សេងទៀត ដោយបានបង្ហាញអំពីទស្សនៈបឋមរបស់ខ្លួនលើអង្គច្បាប់[34]។ ទឡ្ហីករណ៍របស់ ស.ព.អ ក្នុងសំណុំរឿង ០០៤ ដែលលើកឡើងថា

---

[31] សំណុំរឿង ០០២ *សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ដោយបង្អង់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនក្នុងសំណុំរឿងរបស់ នួន ជា* ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ១៥។

[32] សំណុំរឿង ០០២ *ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើររបស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា សុំប្តឹងជំទាស់ក្រុមចៅក្រម* ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E55 កថាខណ្ឌ ៣ (សេចក្តីបញ្ជាក់បន្ថែម)។

[33] *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D249, D355 កថាខណ្ឌ ៨០។

[34] *សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D306 កថាខណ្ឌ ៥ "ដោយទុកបញ្ហានេះមួយឡែកអំពីភាពពាក់ព័ន្ធគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយជម្លោះប្រដាប់អាវុធ ដោយស្ថិតយុត្តាធិការរបស់ អ.វ.ត.ក គេក៏អាចផ្តល់ទ្វីករណ៍ថែមទៀតថា ក) ហាក់ដូចជាគ្មានការជំទាស់ទេថា របបមួយក្នុងគ្រាមានសន្តិភាព បានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដូចជា ទាហានដែលមានជាតិពិន្ទុ ឬជំនឿមួយណានោះ គឺជារបបដែលបានប្រព្រឹត្តបទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទម្លាប់អន្តរជាតិ ពីព្រោះថា លក្ខណៈសម្បត្តិជាយុទ្ធជនរបស់ជនរងគ្រោះ ដោយសារពួកគាត់ជាទាហាននោះ គឺមិនជាប់ពាក់ព័ន្ធ

ស.ច.ស គួរតែត្រូវបានរារាំងពីការផ្តល់អានុភាពលើសេចក្តីពិចារណាជាឯកច្ឆ័ន្ទរបស់ អ.ប.ជ គឺពុំមែនគ្រាន់តែមិនមានមូលដ្ឋានច្បាស់លាស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានដកសិទ្ធិអំណាចរបស់ អ.ប.ជ អនុលោមតាមវិធាន ៣៤(៥) ហេតុដូច្នេះត្រូវតែច្រានចោល។

## III. ស.ព.អ អះអាងដោយមានកំហុសថា សំណើសុំនេះគ្មានអង្គសេចក្តី

14. ស.ព.អ អះអាងដោយមានកំហុសថា គោលការណ៍នៃការប្រព្រឹត្តស្មើភាពគ្នាមិនអាចជាយុត្តិកម្មក្នុងការបញ្ចប់សំណុំរឿង ០០៤ នោះទេ[35]។ ផ្ទុយពីការបកស្រាយខុសរបស់ ស.ព.អ ចំពោះសំណើនេះ មេធាវីការពារក្តីពុំបានសន្និដ្ឋានថា មិនមាន "កាតព្វកិច្ចដាច់ខាតក្នុងការរក្សាទុកសំអាងហេតុ និងសេចក្តីសន្និដ្ឋាននៃរឿងក្តីកន្លងមកឡើយ"[36]។ ប៉ុន្តែ វិធាន ២១(១)(ខ) កំណត់សិទ្ធិទទួលបានការប្រព្រឹត្តស្មើភាពគ្នា ដែលតម្រូវឲ្យប្រព្រឹត្តចំពោះ លោក យឹម ទិត្យ ស្មើភាពគ្នាដូច លោក អោ អាន ពោលគឺបញ្ហាអង្គច្បាប់ដូចគ្នាដែលសម្រេចដោយ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ ត្រូវបកស្រាយ និងអនុវត្តដូចគ្នាក្នុងសំណុំរឿង ០០៤ ដោយសារមិនមានហេតុផលច្បាស់លាស់ណាមួយអាចឲ្យងាកចេញពីការវិភាគរបស់ អ.ជ.ត.ក នោះឡើយ[37]។ ស.ច.ស បានទទួលយកសំអាងហេតុ នៅក្នុងសាលដីការបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/០២[38] ហើយធ្លាប់បានបញ្ជាក់រួចហើយថា "ដោយសារមូលហេតុនៃការគោរពតាមផ្លូវតុលាការចំពោះស្ថាប័នកំពូលដែលពិនិត្យមើលបណ្តឹងសាទុក្ខ យើងមានកាតព្វកិច្ចក្នុងការអនុវត្តតាមខ្លឹមសារនៃច្បាប់យុត្តិសាស្ត្ររបស់ អ.ជ.ត.ក លុះត្រាតែមានសំអាងហេតុពិសេសក្នុងការមិនយល់ស្រប និងប្រកាន់ជំហរជំទាស់ជាចំហ"[39]។ មិនមានអត្ថិភាពនៃហេតុផលបែបនេះ ដើម្បីអាចឲ្យ ស.ច.ស បដិសេធនូវការប្រព្រឹត្តដោយស្មើភាពគ្នាចំពោះ យឹម ទិត្យ និងបដិសេធនូវការអនុវត្តសំអាងហេតុរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/០២ នោះទេ។

---

ទាល់តែសោះនៅក្នុងបរិបទនេះ និង ខ) គ្មានមូលដ្ឋានគិតផ្ទុយពីនេះទេ ប្រសិនបើយុទ្ធជាការបោសសម្អាតបែបនេះបានកើតឡើងនៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ឬក៏ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ"។

[35] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១០-១៦។

[36] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៤។

[37] សំណើរបស់ក្រុមមេធាវីការពារក្តីទៅកាន់ ក.ស.ច.ស កថាខណ្ឌ ១៣-១៧ ជាពិសេស កថាខណ្ឌ ១៦។ ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ២៧-៤២។

[38] សេចក្តីសម្រេចរបស់ ស.ច.ស លើការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២១។

[39] សំណុំរឿង ០០៤/១ *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ១០។

15. ស.ព.អ អះអាងដោយមានកំហុសថា មានហេតុផលច្បាស់លាស់ និងជាក់លាក់អាចដាកចេញពីសាលដីការបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/០២[40]។ ស.ព.អ គ្រាន់តែបញ្ជាក់ឡើងវិញនូវទឡ្ហីករណ៍ ដែលត្រូវបានលើកឡើងដោយ ស.ច.ស[41] អ.ប.ជ[42] និង អ.ជ.ត.ក[43] ដោយមិនបានពន្យល់អំពីមូលហេតុដែលការបដិសេធរបស់ពួកគេបង្កើតជាកំហុសនោះឡើយ[44]។ មិនមានសំណួរថាតើ "ផលប៉ះពាល់" ឬ "ផលវិបាក" នៃការសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ បានធ្វើឱ្យដីកាដំណោះស្រាយមោឃៈនោះទេ ពីព្រោះការរកឃើញជាឯកច្ឆ័ន្ទរបស់ អ.ប.ជ គឺជា*ការរកឃើញថា*

---

[40] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៧-២៨។

[41] ក្នុងការអះអាងថា ត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដោយសំអាងលើអ្វីដែល អ.ប.ជ បានរៀបរាប់ជាឯកច្ឆន្ទថាជា "គោលជំហរស្វ័យប្រវត្តិ "ជាសារវន្ត និងជាកត្តាកំណត់" ដែលជាធាតុផ្សំសំខាន់នៃប្រព័ន្ធគតិយុត្តិរបស់ អ.វ.ត.ក នោះ ស.ព.អ អះអាងបន្ថែមទៀតថា ទឡ្ហីករណ៍ទាំងនេះត្រូវបានបញ្ជូនទៅកាន់ ស.ច.ស នៅក្នុងសំណុំរឿង ០០៣ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឯកសារ D270 កថាខណ្ឌ ១៦។ ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៩-៣១។ សេចក្តីសម្រេចរបស់ ស.ច.ស លើការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២២-២៣, ២៥, ៣៥ និង ៣៦។

[42] ក្នុងការអះអាងថា ការចេញដីកាដំណោះស្រាយពីរមិនត្រូវបានចេញផ្ទុយនឹងច្បាប់នោះ អ.ព.អ អះអាងជាថ្មីថា ទឡ្ហីករណ៍ក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ដែលលើកឡើងថា វិធាន ៦៧(១) ត្រូវអានទៅតាមបរិបទ និងអានផ្គួបផ្គងជាមួយវិធាន ១(២) នៃវិធានផ្ទៃក្នុងគឺ "មានន័យយ៉ាងច្បាស់ថា [ស.ច.ស] ម្នាក់ៗអាចចេញដីកាដំណោះស្រាយបាន"។ *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381)* ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19 កថាខណ្ឌ ១៧៣។ ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៨-២០។ សេចក្តីពិចារណាលើសំណុំរឿង ០០៤ កថាខណ្ឌ ១១១ និង ១១២។

[43] ក្នុងការអះអាងថា សំណុំរឿងនេះត្រូវបញ្ជូនទៅជំនុំជម្រះ ដោយអនុលោមតាមគោលជំហរស្វ័យប្រវត្តិ ទោះបីជាដីកាដំណោះស្រាយមិនត្រូវបានចេញផ្ទុយនឹងច្បាប់ក៏ដោយនោះ ស.ព.អ អះអាងជាថ្មីទៅលើទឡ្ហីករណ៍ដែលបានដាក់ជូនចំពោះមុខ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០៤/២ *បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ឯកសារ កថាខណ្ឌ ៥០-៥៧។ ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៩-៣១។ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៨។

[44] 'អំណះអំណាងដែលពុំមានសក្តានុពលធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធ ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់បានទេនោះ អាចត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលភ្លាមៗ ហើយមិនចាំបាច់ធ្វើការពិចារណាលើអង្គសេចក្តីឡើយ' ដូចជាការលើកឡើងនូវទឡ្ហីករណ៍ដដែលៗ ដោយពុំមានការបង្ហាញឱ្យឃើញថា កាបដិសេធអំណះអំណាងទាំងនោះនាំឱ្យមានកំហុសទេនោះ។ សំណុំរឿង ០០១ *សាលដីកា* ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២០។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា តល់នឹង Stanišić និង Simatović* សំណុំរឿង IT-03- 69-A "សាលដីកា" ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២២។

*គ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះណាមួយត្រឹមត្រូវដែលត្រូវបន្តទៅធ្វើសវនាការនោះឡើយ*[45]។ ដោយបានប្រកាសថា ការចេញដីកាដំណោះស្រាយចំនួនពីរ គឺមោឃៈ មតិដោយឡែករបស់ចៅក្រម អ.ប.ជ ក្នុងសំណុំរឿង ០០៤ គឺ "មិនពាក់ព័ន្ធ" "ជាការអនុវត្តដែលពុំចាំបាច់" និង "ជារឿងលែងចាំបាច់"[46]។ ស.ព.អ ពុំបានផ្ដល់ហេតុផលច្បាស់លាស់ អាចឱ្យ ស.ច.ស ងាកចេញពីសាលដីការបស់ អ.ជ.ត.ក ដែលសម្រេចថា ដីកាដំណោះស្រាយទាំងនោះគឺមោឃៈ និងពិចារណាថាតើការចេញដីកាដោយខុសច្បាប់របស់ពួកគេ "បណ្ដាលឱ្យមានភាពមិនយុត្តិធម៌" ឬ "លទ្ធផលមិនយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ" និងកត្តានានាដូចជា ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ការខាតបង់សង្គមក្នុងការទប់ស្កាត់ករណីនេះកុំឱ្យដំណើរការទៅមុខ ផលប្រយោជន៍របស់ភាគីទាំងអស់ និងសមាមាត្រនៃសំណងចំពោះការខូចខាតដូចបានចោទប្រកាន់[47]។ នៅក្នុងសំណុំរឿង ០០៤ មិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានសុពលភាពនោះឡើយ។

## IV. សេចក្ដីសន្និដ្ឋាន

16. ស.ព.អ បានព្យាយាមអស់រយៈពេល ១៥ឆ្នាំ ដើម្បីចោទប្រកាន់លោក យឹម ទិត្យ ដោយគ្មានការយល់ព្រម និងការគាំទ្រពីសហសេវិករបស់ខ្លួនគឺ សហព្រះរាជអាជ្ញាជាតិ និងបានធ្វើតាមគ្រប់មធ្យោបាយចាំបាច់ទាំងអស់ ដើម្បីដាក់ចេញគោលបំណងរបស់សមភាគីអន្តរជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ការទទូចមិនចេះចប់មិនចេះហើយរបស់ ស.ព.អ ថា សំណុំរឿង ០០៤ ដំណើរការទៅជំនុំជម្រះនោះ ជំទាស់ដោយមិនត្រឹមត្រូវចំពោះបញ្ហាអង្គច្បាប់ដែលបានសម្រេចរួចហើយ ដែលចំណុចនេះបង្ហាញអំពីការប្រឆាំងជាមូលដ្ឋានទៅនឹងវិធាន ការមិនគោរព និងការមិនអនុវត្តតាមសេចក្ដីសម្រេចតាមផ្លូវតុលាការនៅ អ.វ.ត.ក និងការមិនអើពើចំពោះសិទ្ធិរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ។ ចម្លើយតបរបស់ ស.ព.អ ដែលចោទប្រកាន់ ស.ច.ស ថាមានភាពលម្អៀង គឺធ្វើឡើងដោយគ្មានវិជ្ជាជីវៈ និងមិនសមស្រប

---

[45] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៦៧។ សំណុំរឿង ០០៤/២ *សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/០២ ស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល* ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ ឯកសារ E004/2/3 កថាខណ្ឌ ១៥-១៩។ *សូមមើលផងដែរ សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់* ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ឯកសារ D386 កថាខណ្ឌ ១៤-១៧។

[46] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៥៣, ៦៧ (សេចក្ដីបញ្ជាក់បន្ថែមក្នុងឯកសារដើម)។

[47] ចម្លើយតបសបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៨-១៩។

តាមតួនាទីជា ស.ព.អ ដូចបានកំណត់ក្នុងមាត្រា ៦ នៃកិច្ចព្រមព្រៀង និងមាត្រា ២១*ថ្មី* នៃច្បាប់ អ.វ.ត.ក។ និយាយឱ្យខ្លី វាដល់ពេលត្រូវបញ្ឈប់បញ្ហានេះ។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយគោរពដល់សហចៅក្រមស៊ើបអង្កេត៖

១. **ច្រានចោល**ចម្លើយតបរបស់ ស.ព.អ និង

២. **យល់ព្រម**តាមសំណើសុំឱ្យបញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង 004 ទៅក្នុងបណ្ណសារជាបន្ទាន់ ។

សូមលោកចៅក្រមមេត្តាទទួលយកការឆ្លើយតបនេះដោយគោរព។

**សូ មូស្សេទ្ធី** **Suzana TOMANOVIĆ**

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១